VICTORIAN CURRICULUM AND ASSESSMENT AUTHORITY

Victoria
The Place To Be

# ការវិលទៅសិក្សាវិញ

**សេចក្តីណែនាំអំពី VCE និង VCAL**

ព័ត៌មាននៅក្នុងឯកសារនេះនឹងជួយលោកអ្នក បើលោកអ្នក:

- មានអាយុលើសពី ១៨ ឆ្នាំ ហើយ
- ចាប់អារម្មណ៍ក្នុងការវិលទៅសិក្សានៅកំរិតមធ្យមសិក្សាជាន់ខ្ពស់(លើសពីថ្នាក់ទី ១០)វិញ។

លោកអ្នកមានជំរើសទាំងឡាយ ដោយមានរួមទាំង:

- វិញ្ញាបនបត្រអប់រំនៃរដ្ឋវិចតូរីយ៉ា (VCE)
- វិញ្ញាបនបត្ររៀនសូត្រសំរាប់អនុវត្តន៍នៃរដ្ឋវិចតូរីយ៉ា (VCAL)។

ទាំង VCE និងទាំង VCAL អាចមានរួមទាំងការសិក្សាអប់រំនិងហ្វឹកហ្វឺនវិជ្ជាជីវៈ (VET)

ការសិក្សាបន្ថែមទៀតអាចជាមាគ៌ាមួយឆ្ពោះទៅកាន់:

- ការសិក្សាថ្នាក់ឧត្តមសិក្សា
- ឱកាសធ្វើការងារដែលផ្តល់ការពេញចិត្តថែមទៀត
- អាជីពថ្មីៗ
- ការបង្កើនចំណេះផ្ទាល់ខ្លួន

## VCE
## វិញ្ញាបនបត្រអប់រំនៃរដ្ឋវិចតូរីយ៉ា (Victorian Certificate of Education)

### សិស្សដែលវិលទៅសិក្សាវិញ – VCE

VCE គឺជាវិញ្ញាបនបត្រអប់រំមធ្យមសិក្សាជាន់ខ្ពស់ ដែលមានសមាសភាពកម្មវិធីសិក្សាទូទៅ (មុខវិជ្ជា VCE) និងកម្មវិធីមកពីលក្ខណៈសម្បត្តិសិក្សាអប់រំនិងហ្វឹកហ្វឺនវិជ្ជាជីវៈ (VCE VET)។

### សិស្សទាំងឡាយដែលសិក្សា unit កាលពីមុនខ្លះរបស់ VCE

បើលោកអ្នកបានបំពេញ unit ខ្លះរបស់ VCE ហើយមានបំណងសិក្សាបន្ថែមទៀតដើម្បីបំពេញតម្រូវការទាំងពួងនៃ VCE, លោកអ្នកមានជំរើស:

- បំពេញតម្រូវការតិចបំផុតទាំងឡាយដែលអនុវត្តចំពោះសិស្សសាលារៀន (unit ចំនួន ១៦ ដែលមានរួមទាំង unit បី មកពីក្រុមអង់គ្លេស និងលំដាប់ចំនួនបីនៃ unit ទី ៣ និងទី ៤ នៅក្នុងមុខវិជ្ជានានាក្រៅពីអង់គ្លេស)
- ចុះឈ្មោះសិក្សាជាជនពេញវ័យ និងបំពេញសព្វគ្រប់នូវ unit ចំនួនប្រាំបី។

### VCE សំរាប់ជនពេញវ័យ

លោកអ្នកត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យពីរ ដើម្បីចុះឈ្មោះជាជនពេញវ័យ។ លោកអ្នកត្រូវតែ:

- មិនបានសិក្សាពេញពេលនៅកំរិតមធ្យមសិក្សាសំរាប់មួយឆ្នាំសិក្សាទាំងមូល នៅមុនពេលចុះឈ្មោះនៅក្នុងឆ្នាំដំបូងជាជនពេញវ័យ និង
- មានអាយុយ៉ាងតិច ១៨ ឆ្នាំ នៅនឹងថ្ងៃទី ១ ខែមករា នៃឆ្នាំចុះឈ្មោះសិក្សា។

### សិទ្ធិសិក្សា VCE

ដើម្បីបំពេញតាមតម្រូវការទាំងឡាយសំរាប់ទទួលសញ្ញាប័ត្រ VCE សិស្សដែលវិលទៅសិក្សាវិញ(សិស្សពេញវ័យ)ត្រូវបំពេញគួរជាទីពេញចិត្តយ៉ាងតិច unit ចំនួនប្រាំបី ដោយមានរួមទាំង:

- unit ចំនួនពីរមកពីក្រុមអង់គ្លេសនៅគ្រប់កំរិតទាំងអស់ (ពោលគឺមកពី unit ទី ១, ទី ២, ទី ៣ ឬទី ៤) និង
- លំដាប់ចំនួនបីនៃ unit ទី ៣ និងទី ៤ នៅក្នុងមុខវិជ្ជាក្រៅពីអង់គ្លេស។

សំរាប់ការចូលសិក្សាថ្នាក់ឧត្តមសិក្សា unit អង់គ្លេសត្រូវតែនៅនឹងកំរិត unit ទី ៣ និងទី ៤។

កម្មវិធី VCE VET អាចរាប់បញ្ចូលទៅក្នុងការបំពេញគួរជាទីពេញចិត្តនូវ VCE ។

### សិស្សដែលមានឥណទាន (credit) សំរាប់មុខវិជ្ជាទាំងឡាយនៅមុន VCE

សិស្សដែលចង់បាន VCE របស់ខ្លួនដោយប្រើលទ្ធផលនៃ HSC, TOP ឬ T12 ត្រូវតែមានលទ្ធផលគួរជាទីពេញចិត្តសំរាប់ unit ចំនួនប្រាំបី ដោយមានរួមទាំង unit ពីរមកពីក្រុមអង់គ្លេស ឲ្យតែ unit ទាំងប្រាំបីនោះត្រូវបានសិក្សានៅនឹងកំរិត unit ទី ៣ និងទី ៤ (ថ្នាក់ទី ១២)។

### សិស្សដែលបានឈប់សិក្សា VCE របស់ខ្លួន ក្នុងអម្លុងការសិក្សានៅឆ្នាំមុននោះ

ជាការមិនចាំបាច់ឡើយក្នុងការរៀនឡើងវិញនូវ unit ទី ៣ នៃមុខវិជ្ជា VCE (ឲ្យតែបានបំពេញគួរជាទីពេញចិត្តនូវ unit ទាំងនោះ) ប៉ុន្តែលោកអ្នកគួរតែសិក្សាឡើងវិញ បើលោកអ្នកគ្រោងប្រឡងនៅចុងឆ្នាំ។ ជាការចាំបាច់ក្នុងការសិក្សាឡើញវិញនូវ unit ទី ៣ នៃមុខវិជ្ជា VCE ដើម្បីទទួលបាននូវពិន្ទុមុខវិជ្ជា។

### សិស្សដែលមានបំណងរៀនឡើងវិញនូវ unit របស់ VCE

unit របស់ VCE ដែលលោកអ្នកអាចសិក្សានោះ គឺគ្មានកំរិតចំនួនឡើយ។ គេក៏គ្មានផាកពិន័យចំពោះការរៀន unit ទាំងពួង ឡើងវិញផងដែរ។ ការរៀនឡើងវិញនូវកំរិត unit ទី ៣ និងទី ៤ គឺជាវិធីមួយក្នុងការកែលំអពិន្ទុមុខវិជ្ជារបស់លោកអ្នក និង កែលំអឱកាសលោកអ្នកក្នុងការចូលទៅកាន់វគ្គសិក្សាណាមួយ។

### តម្រូវការនៃការទទួលចូល

ទោះជាគ្មានតម្រូវការនៃការទទួលចូលផ្លូវការសំរាប់ការសិក្សា VCE ក្នុងភាពជាជនពេញវ័យក្តី ក៏លោកអ្នកគួរទាក់ទងស្ថាប័នផ្តល់ ការសិក្សាអប់រំសហគមន៍ជនពេញវ័យ (ACE), វិជ្ជាស្ថានបច្ចេកទេសនិងសិក្សាអប់រំបន្ថែម (TAFE) ឬមណ្ឌលសំរាប់ការ សិក្សាអប់រំជនពេញវ័យ (CAE) អំពីតម្រូវការសិក្សាអប់រំយ៉ាងតិចបំផុតដែរ។ ចំពោះមុខវិជ្ជាខ្លះ លោកអ្នកគួរបំពេញសព្វគ្រប់នូវ unit ទី ១ និងទី ២ មុនពេលចុះឈ្មោះរៀន unit ទី ៣ និងទី ៤ ។

### ការបំពេញសព្វគ្រប់នូវ VCE

សិស្សពេញវ័យមិនចាំបាច់រៀនចប់សព្វគ្រប់នូវ VCE នៅក្នុងពេលមួយឆ្នាំនោះទេ។ សិស្សទាំងនេះអាចសិក្សា unit ទាំងឡាយ នៅក្នុងពេលជាច្រើនឆ្នាំ ប៉ុន្តែ unit ទី ៣ និងទី ៤ នៃមុខវិជ្ជាណាមួយ ត្រូវតែបំពេញសព្វគ្រប់នៅក្នុងពេលមួយឆ្នាំប្រក្រតិទិន ដើម្បីឲ្យទទួលបានពិន្ទុមុខវិជ្ជា។

### ពេលត្រូវសិក្សា

មុខវិជ្ជាភាគច្រើននៃ VCE តម្រូវឲ្យមានការទៅចូលរៀននៅតាមថ្នាក់ ចំនួនពីបីទៅបួនម៉ោងក្នុងមួយអាទិត្យ។ ការទៅរៀននេះ ប្រហែលជានៅក្នុងពេលតែមួយលើក ឬពីរលើកក្នុងមួយអាទិត្យ។ សិស្សក៏ត្រូវបានរំពឹងឲ្យសិក្សានៅក្រៅថ្នាក់រៀនផងដែរ។

## ការឲ្យពិន្ទុនៅក្នុង VCE

ការប្រឡងជាប់ VCE ផ្អែកលើការបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ unit ទាំងឡាយដែលជាមុខវិជ្ជានៃ VCE ។ សេចក្តី សំរេចចិត្តអំពីការបំពេញសព្វគ្រប់គួរជាទីពេញចិត្ត នឹងផ្អែកលើសមត្ថភាពរបស់លោកអ្នកក្នុងការទទួលលទ្ធផលទាំងឡាយ។

លទ្ធផលទាំងនេះត្រូវបានបញ្ជាក់នៅក្នុងគំរោងរៀបចំមុខវិជ្ជាសំរាប់មុខវិជ្ជានីមួយៗរបស់ VCE ។ លទ្ធផលទាំងនេះពណ៌នាអំពី តំរិះវិជ្ជានិងជំនាញការដែលលោកអ្នកគួរតែអាចបង្ហាញឲ្យឃើញ នៅនឹងពេលដែលលោកអ្នកបានបំពេញសព្វគ្រប់នូវ unit ណា មួយ។

ការឲ្យពិន្ទុ VCE មានពីរប្រភេទ – ការឲ្យពិន្ទុនៅនឹងសាលារៀន និងការប្រឡង។

### ការឲ្យពិន្ទុនៅសាលារៀន

ការឲ្យពិន្ទុនៅសាលារៀនមានពីរប្រភេទ។ ប្រភេទទីមួយត្រូវបានហៅថា កិច្ចការឲ្យពិន្ទុនៅសាលារៀន (School-assessed Coursework) ដែលសិស្សត្រូវបំពេញសព្វគ្រប់នូវកិច្ចការដាក់ពិន្ទុដែលបញ្ជាក់នៅក្នុងគំរោងរៀបចំមុខវិជ្ជា។ សិស្សត្រូវធ្វើកិច្ច ការទាំងនេះជាចំបងនៅក្នុងពេលសិក្សានៅក្នុងថ្នាក់រៀន ហើយមានរួមទាំងតែងសេចក្តី របាយការណ៍ និងការសិក្សាករណី។

មុខវិជ្ជាពីរបីនៅក្នុងផ្នែកចក្ខុសិល្បៈនិងបច្ចេកវិជ្ជា មានការឲ្យពិន្ទុប្រភេទទីពីរដែលជាកិច្ចការមួយឲ្យពិន្ទុនៅសាលារៀន។ កិច្ចការនេះ គឺដូចគ្នាសំរាប់សិស្សរាល់រូបដែលចុះឈ្មោះរៀនមុខវិជ្ជាណាមួយ ហើយ VCAA ជាអ្នកកំណត់ចំណុចជាក់លាក់ទាំងឡាយ។

**ការប្រឡងនៅខាងក្រៅ**

ការប្រឡងនៅខាងក្រៅត្រូវបានកំណត់និងឲ្យពិន្ទុដោយអាជ្ញាធរកម្មវិធីសិក្សានិងឲ្យពិន្ទុរដ្ឋវិកតូរីយ៉ា (Victorian Curriculum and Assessment Authority) ។ ការប្រឡងភាគច្រើនត្រូវបានធ្វើឡើងនៅខែតុលា ឬ វិច្ឆិកា ប៉ុន្តែមុខវិជ្ជាមួយចំនួនតូចក៏មានការប្រឡងនៅខែមិថុនាផងដែរ។

**ពិន្ទុមុខវិជ្ជា**

សិស្សដែលបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ unit ទី ៣ និងទី ៤ នៃមុខវិជ្ជាណាមួយរបស់ VCE និងតម្រូវការនៃការឲ្យពិន្ទុមានសិទ្ធិទទួលពិន្ទុមុខវិជ្ជា។ ពិន្ទុមុខវិជ្ជាត្រូវបានប្រើការ បើលោកអ្នកដាក់ពាក្យសុំចូលថ្នាក់ឧត្តមសិក្សា។

**តេស្តស្នាដៃទូទៅ (GAT)**

GAT គឺជាផ្នែកសំខាន់ចាំបាច់មួយនៃ VCE ។ តេស្តនេះផ្តល់គោលការណ៍នៃការឆែកមើលការធានាគុណភាពអំពីការឲ្យពិន្ទុនៃការប្រឡង។ សិស្សណាមួយដែលចុះឈ្មោះនៅក្នុងលំដាប់ unit ទី ៣ និងទី ៤ នៃ VCE ឬ VCE VET ត្រូវបានរំពឹងថានឹងចូលរួមក្នុងការធ្វើតេស្ត GAT ។

ដើម្បីទទួលព័ត៌មានបន្ថែមអំពី VCE: **www.vcaa.vic.edu.au/vce/index.html**

## VCAL
## វិញ្ញាបនបត្ររៀនសូត្រសំរាប់អនុវត្តន៍នៃរដ្ឋវិចតូរីយ៉ា (Victorian Certificate of Applied Learning)

### សិស្សដែលវិលទៅសិក្សាវិញ – VCAL

VCAL គឺជាវិញ្ញាបនបត្រសិក្សាអប់រំមធ្យមសិក្សាជាន់ខ្ពស់តម្រូវឲ្យអនុវត្តន៍ផ្ទាល់ ដែលផ្តល់ឲ្យសិស្សនូវបទពិសោធន៍ទាក់ទងនឹងការងារអនុវត្តន៍ ព្រមទាំងឱកាសដើម្បីបង្កើតជំនាញការអក្ខរកម្មនិងការចេះគិតលេខ ហើយនិងជំនាញការយល់ដឹងផ្ទាល់ខ្លួន។

ភាពអាចផ្លាស់ប្តូរបានរបស់ VCAL អាចឲ្យសិស្សចាប់យកកម្មវិធីមួយដែលសមរម្យតាមចំណាប់អារម្មណ៍និងសេចក្តីត្រូវការរៀនសូត្ររបស់ខ្លួន។ ផ្នែកនិង unit ដែលទទួលស្គាល់ទាំងឡាយ ត្រូវបានជ្រើសយកចេញពីប្រភេទចាំបាច់ខានមិនបានទាំងបួនដូចតទៅនេះ:

- ជំនាញការអក្ខរកម្មនិងការចេះគិតលេខ
- ជំនាញការជាក់លាក់ផ្នែកឧស្សាហកម្ម
- ជំនាញការទាក់ទងនឹងការងារ
- ជំនាញការបង្កើតការយល់ដឹងផ្ទាល់ខ្លួន។

#### តម្រូវការនៃការទទួលចូល

VCAL មានកំរិតចំនួនបី – បឋម មធ្យម និង ខ្ពស់។ សិស្សចាប់ផ្តើមនិងបំពេញសព្វគ្រប់នូវ VCAL របស់ខ្លួននៅនឹងកំរិតដែលសមស្របតាមសេចក្តីត្រូវការនិងសមត្ថភាពរបស់ខ្លួន។ គ្មានតម្រូវការនៃការទទួលចូលសំរាប់ VCAL ទេ ហើយសិស្សអាចប្រើពេលយូរទៅតាមសេចក្តីត្រូវការ ដើម្បីបំពេញសព្វគ្រប់នូវវិញ្ញាបនបត្រនៅគ្រប់កំរិតទាំងអស់។

#### ពេលសិក្សា

VCAL ត្រូវបានបង្កើតឡើងសំរាប់សិស្សថ្នាក់ទី ១១ និងទី ១២ ។ វិញ្ញាបនបត្រ VCAL និងរបាយការណ៍លទ្ធផល នឹងត្រូវចេញទៅឲ្យសិស្សដែលបំពេញសព្វគ្រប់ដោយជោគជ័យនូវកម្មវិធី VCAL នៅនឹងកំរិតនីមួយៗ។ សិស្សជាច្រើនបំពេញសព្វគ្រប់នូវកំរិត VCAL មួយ នៅក្នុងពេលមួយឆ្នាំ។

### ការឲ្យពិន្ទុនៅក្នុង VCAL

VCAL មានវគ្គសិក្សាឬវិញ្ញាបនបត្រដែលទទួលស្គាល់ទាំងឡាយ។ កម្មវិធី VCAL មួយ ត្រូវបានឲ្យពិន្ទុដោយគ្រូបង្រៀនឲ្យសមស្របទៅតាមតម្រូវការនៃការឲ្យពិន្ទុសំរាប់ផ្នែកនីមួយៗនៃកម្មវិធីនោះ។

ដើម្បីទទួលព័ត៌មានបន្ថែមអំពី VCAL: **www.vcaa.vic.edu.au/vcal/index.html**

## VET
## ការសិក្សាអប់រំនិងហ្វឹកហ្វឺនវិជ្ជាជីវៈ (Vocational Education and Training)

វិញ្ញាបនបត្រវិជ្ជាជីវៈដែលទទួលស្គាល់នៅទូទាំងប្រទេសគឺមានជាច្រើន ហើយលោកអ្នកអាចរៀនយកវិញ្ញាបនបត្រនេះជាផ្នែកនៃ ឬក្នុងវង្វង់ VCE ឬ VCAL ។ ការធ្វើដូចនេះអាចឲ្យលោកអ្នកបំពេញសព្វគ្រប់ទាំង VCE ឬ VCAL និងលក្ខណៈសម្បត្តិជាជីវៈមួយនៅគ្រាជាមួយគ្នា។

### VCE VET

VCAA ផ្តល់ឥណទានដោយផ្ទាល់នៅក្នុង VCE សំរាប់វិញ្ញាបនបត្រវិជ្ជាជីវៈមួយឈុតជាក់លាក់ ដែលត្រូវបានហៅថា កម្មវិធី VCE VET ។ កម្មវិធីទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុង VCE ជាមួយនឹងកំរិតទទួលស្គាល់នៃ unit ទី ១ – unit ទី ២ និង unit ទី ៣ ហើយនិង unit ទី ៤ ។

កម្មវិធី VCE VET អាចត្រូវបានរួមបញ្ចូលនៅក្នុងទាំង VCE និងទាំង VCAL ។

កម្មវិធី VCE VET អាចត្រូវបានផ្តល់ជូននៅតាមសាលារៀន, ស្ថាប័នផ្តល់ការសិក្សាអប់រំសហគមន៍ជនពេញវ័យ (ACE), វិជ្ជាស្ថានបច្ចេកទេសនិងសិក្សាអប់រំបន្ថែម (TAFE), មណ្ឌលសំរាប់ការសិក្សាអប់រំជនពេញវ័យ (CAE) ឬអង្គការហ្វឹកហ្វឺនឯកជនដែលចុះឈ្មោះត្រឹមត្រូវ (RTOs)។

កម្មវិធី VCE VET មាននៅក្នុងផ្នែកឧស្សាហកម្មមួយចំនួនផ្សេងគ្នា ដោយមានរួមទាំងអាជីវកម្ម បដិសណ្ឋារកិច្ច បច្ចេកវិជ្ជាព័ត៌មាន និងប្រព័ន្ធពហុព័ត៌មាន។

ដើម្បីទទួលព័ត៌មានបន្ថែមអំពីកម្មវិធី VCE VET: **www.vcaa.vic.edu.au/vet/index.html**

### BLOCK RECOGNITION (ការទទួលស្គាល់ប្លុក)

វិញ្ញាបនបត្រវិជ្ជាជីវៈផ្សេងទៀតក៏អាចរួមចំណែកឆ្ពោះទៅកាន់ការបំពេញគួរជាទីពេញចិត្តនូវ VCE ផងដែរ។ បើលោកអ្នកបានបំពេញសព្វគ្រប់នូវកំរិតវិញ្ញាបនបត្រទី II ឬខ្ពស់ជាងនេះ នៅក្នុងផ្នែកមួយដែលគ្មាននៅក្នុងកម្មវិធី VCE VET, នោះ VCAA អាចផ្តល់ឥណទានឲ្យលោកអ្នក។ នេះត្រូវបានហៅថា Block Credit Recognition (ការទទួលស្គាល់ឥណទានប្លុក)។ ការហ្វឹកហ្វឺនវិញ្ញាបនបត្រទី II អាចរួមចំណែកដល់ VCE នៅកំរិត unit ទី ១ – unit ទី ២ និងការហ្វឹកហ្វឺនវិញ្ញាបនបត្រទី III និងខ្ពស់ជាងនេះ អាចរួមចំណែកដល់កំរិត unit ទី ៣ – unit ទី ៤។

ដើម្បីទទួលព័ត៌មានបន្ថែមអំពី Block Credit Recognition: (03) 9651-4300 ឬ 1800 134 197

## តើមានអ្វីទៀតក្រោយពី VCE ឬ VCAL?

### VCE

ក្រោយពីបំពេញ VCE ចប់សព្វគ្រប់ សិស្សអាចដាក់ពាក្យសុំការសិក្សាថ្នាក់ឧត្តមសិក្សាក្នុងរដ្ឋវិកតូរីយ៉ា តាមរយៈមណ្ឌលទទួលចូលឧត្តមសិក្សារដ្ឋវិកតូរីយ៉ា (Victorian Tertiary Admissions Centre [VTAC])។ VTAC នឹងគណនាពិន្ទុមួយសំរាប់ចូលឧត្តមសិក្សាជាតិ (Equivalent National Tertiary Entrance Rank [ENTER]) ក្រោយពីវាស់កំរិតពិន្ទុមុខវិជ្ជាទាំងឡាយនៃ VCE របស់លោកអ្នក។ ដើម្បីទទួលព័ត៌មានបន្ថែម: **www.vtac.edu.au**

សិស្ស VCE ពេញវ័យគួរកត់សំគាល់ថា unit អង់គ្លេសទាំងឡាយរបស់ខ្លួន ត្រូវនៅនឹងកំរិត unit ទី ៣ និងទី ៤ ដើម្បីឲ្យលោកអ្នកមានសិទ្ធិទទួល ENTER មួយ។

សិស្សដែលរៀន unit ទាំងឡាយនៃ VCE ឡើងវិញដើម្បីកែលំអពិន្ទុរបស់ខ្លួន គួរកត់សំគាល់ថា បើខ្លួនដាក់ពាក្យសុំចូលឧត្តមសិក្សាតាមរយៈ VTAC នោះ ENTER នឹងត្រូវបានគណនាដោយផ្អែកលើពិន្ទុមុខវិជ្ជាខ្ពស់បង្អស់ ដោយមិនគិតអំពីឆ្នាំដែលបានទទួលពិន្ទុនោះឡើយ។

### VCE VET

កម្មវិធី VCE VET ខ្លះមានការពិនិត្យវាយតម្លៃឲ្យពិន្ទុ – មុខវិជ្ជាទាំងនេះនឹងត្រូវបានចាត់ទុកថាដូចគ្នានឹងមុខវិជ្ជាទទួលពិន្ទុនៃ VCE នៅក្នុងការគណនា ENTER ដែរ។ កម្មវិធី VCE VET ដែលគ្មានការពិនិត្យវាយតម្លៃឲ្យពិន្ទុ អាចរួមចំណែកដល់ ENTER ក្នុងភាពជាពិន្ទុបន្ថែម។ ដើម្បីទទួលព័ត៌មានបន្ថែម: **www.vtac.edu.au**

### VCAL

សិស្សដែលបំពេញ VCAL ចប់សព្វគ្រប់ ទំនងជាចាប់អារម្មណ៍ក្នុងការបន្តចូលទៅហ្វឹកហ្វឺននៅវិជ្ជាស្ថាន TAFE ដោយរៀនធ្វើជាកូនជាងឬដើម្បីឲ្យមានការងារធ្វើ។ លោកអ្នកអាចទទួលព័ត៌មានបន្ថែមអំពីវគ្គសិក្សា TAFE ដោយបើកមើល **www.education.vic.gov.au/tafecourses/**

សិស្សមាន VCAL កំរិតមធ្យមឬខ្ពស់ ដែលបន្ទាប់មកចុះឈ្មោះនៅក្នុង VCE នៅឆ្នាំបន្ទាប់មកទៀត នឹងមានសិទ្ធិសិក្សា VCE បើសិស្សទាំងនោះបំពេញសព្វគ្រប់គួរជាទីពេញចិត្តនូវ:

- unit ចំនួនពីរមកពីក្រុមអង់គ្លេស VCE
- លំដាប់ចំនួនបីនៃ unit ទី ៣ និងទី ៤ នៃ VCE នៅក្នុងមុខវិជ្ជាទាំងពួងក្រៅពីអង់គ្លេស។

លោកអ្នកអាចទទួលព័ត៌មានបន្ថែមនៅឯ **www.vcaa.vic.gov.au**

សិស្សដែលមានបំណងចូលធ្វើការក្រោយពីបំពេញ VCE ឬ VCAL សព្វគ្រប់ អាចទាក់ទង Centrelink ដើម្បីទទួលព័ត៌មាននិងឱវាទអំពីអាជីពទាំងឡាយ: **www.centrelink.gov.au**

## ទីកន្លែងសិក្សា VCE និង VCAL

វគ្គសិក្សា VCE និង VCAL មាននៅតាមស្ថាប័នមួយចំនួនផ្សេងៗគ្នា សំរាប់អ្នកវិលទៅសិក្សាវិញ:

- ស្ថាប័នផ្តល់ការសិក្សាអប់រំសហគមន៍ជនពេញវ័យ (Adult Community Education [ACE]) (**www.acfe.vic.gov.au**)
- វិជ្ជាស្ថានបច្ចេកទេសនិងសិក្សាអប់រំបន្ថែម (Technical and Further Education [TAFE]) (**www.education.vic.gov.au/tafecourses**)
- សេវាសិក្សាអប់រំពហុវប្បធម៌ជនពេញវ័យ (Adult Multicultural Education Services [AMES]) (**www.ames.vic.edu.au**)
- មណ្ឌលសំរាប់ការសិក្សាអប់រំជនពេញវ័យ (Centre for Adult Education [CAE]) (**www.cae.edu.au**)

បញ្ជីពេញលេញនៃស្ថាប័នផ្តល់ជូនជនពេញវ័យ មាននៅឯ:
**http://schlprv.vcaa.vic.edu.au/schoolsstudiessearch**
រើសយកផ្នែក ‘Adult’ សំរាប់ស្ថាប័នផ្តល់ ACE និង TAFE ។

បើលោកអ្នកមានអាយុតិចជាង ២០ ឆ្នាំ នៅនឹងថ្ងៃទី ១ មករានៃឆ្នាំដែលលោកអ្នកសិក្សា VCE ឬ VCAL លោកអ្នកនឹងទទួលការធានាថា លោកអ្នកនឹងទទួលកន្លែងមួយនៅតាមស្ថាប័នជាច្រើនខាងលើនេះដែលផ្តល់សេវាជូនជនពេញវ័យ។

## ការសិក្សាដោយមិនចាំបាច់ទៅចូលរួមនៅឯមណ្ឌលសិក្សា (Study by correspondence)

សិស្សពេញវ័យអាចសិក្សាដោយមិនចាំបាច់ទៅចូលរួមនៅមណ្ឌលសិក្សា ដោយចុះឈ្មោះនៅឯមណ្ឌលសិក្សាអប់រំពីចម្ងាយរដ្ឋវិកតូរីយ៉ា (Distance Education Centre Victoria [DECV])។
ដើម្បីទទួលព័ត៌មានបន្ថែម: **www.distance.vic.edu.au**

## ដើម្បីទទួលព័ត៌មានបន្ថែម

សូមទាក់ទង: Victorian Curriculum and Assessment Authority
41 St Andrews Place, East Melbourne, 3002
ទូរស័ព្ទ (03) 9651 4328 or 1800 137 195
អ៊ីមែល: vcaa@edumail.vic.gov.au